ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៨៧៥ ធទឧ

សេចក្តីជូនដំណឹងបន្ថែម

ស្តីពី ស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកជំនន់ នៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងបន្ថែម ដល់សាធារណជនឱ្យបានជ្រាបថា ៖ ប្រព័ន្ធសម្ពាធទាប ដែលបានកើតឡើងកាលពីថ្ងៃទី 24 ខែសីហា ឆ្នាំ 2014 និងអូសកាត់ពីលើអាងទន្លេមេគង្គ ក្នុងប្រទេសថៃ និងប្រទេសឡាវ នោះ បច្ចុប្បន្នបានរំកិលចុះមកទិសខាងត្បូង ត្រង់ព្រំប្រទល់ប្រទេសកម្ពុជា-ឡាវ ។ ទន្ទឹមនឹងនេះ សម្ពាធទាបមួយ នៃប្រព័ន្ធសម្ពាធទាបនេះ បានគ្របដណ្តប់លើព្រះរាជាណាចក្រកម្ពុជាស្ទើរទាំងមូល ។

ស្ថានភាពអាកាសធាតុបែបនេះ នឹងបង្កឱ្យ ៖

1- ព្រះរាជាណាចក្រកម្ពុជា នឹងបន្តធ្លាក់ភ្លៀងកាន់តែច្រើនក្នុងក្របខណ្ឌទូទាំងប្រទេស ចាប់ពីថ្ងៃទី 30 ខែសីហា ឆ្នាំ 2014 អូសបន្លាយក្នុងរយៈពេល 01 សប្តាហ៍ ដែលអាចបណ្តាលឱ្យខេត្តមួយចំនួន រួមមាន ៖ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី **ប្រឈមនឹងជំនន់ទឹកភ្លៀង** ។

2- ប្រព័ន្ធសម្ពាធទាបនេះ ក៏នឹងធ្វើឱ្យមានភ្លៀងធ្លាក់ច្រើននៅអាងទន្លេមេគង្គភាគខាងលើ ដែលបង្កឱ្យកំពស់ទឹកទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ កើនឡើងជាបន្តបន្ទាប់ ចាប់ពីដើមខែកញ្ញា តទៅ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន ជ្រាបជាព័ត៌មាន និងសូមបង្កើនការយកចិត្តទុកដាក់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងបន្តតាមដានយ៉ាងយកចិត្តទុកដាក់លើបាតុភូតធម្មជាតិនេះ ហើយនឹងធ្វើការជូនដំណឹងបន្ថែមទៀត ក្នុងករណីចាំបាច់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥

47 Preah Norodom B V D. Phnom Penh, Fax/Phone: (855) 23.725 989 / (855) 23.426 345 E-mail : mowram@cambodia.gov.kh